Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

# 2024 PUBLIC EXAMINATION

# Khmer

## Continuers Level

**Tuesday 15 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2024*

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 1**

*Vocabulary*
មគ្គុទ្ទេសក៍ទេសចរណ៍ — tour guide

1. (a) Identify *two* experiences that this tour offers. **2**

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

(b) Explain the discounts that are available. **2**

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) Who is the intended audience of this text? **1**

(b) How does the speaker engage their audience? Use evidence from the text to support your answer. **4**

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. (a) Explain Makara’s use of the expression « វប្បធម៌រលត់ ជាតិរលាយ» in this conversation. **2**

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

(b) What is Vireak’s position on the issue? Support your answer with evidence from the text. **4**

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

**Part B** (Questions 4 to 6)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 4**

4. (a) Who is leaving this message? **1**

តើអ្នកណាជាអ្នកផ្ញើសារសំឡេងនេះ?

____________________________________________________

____________________________________________________

(b) How is the speaker feeling? Support your answer with evidence from the text. **2**

តើអ្នកនិយាយមានអារម្មណ៍ដូចម្ដេច?

គាំទ្រចម្លើយរបស់អ្នកដោយស្រង់ភស្តុតាងពីអត្ថបទ។

____________________________________________________

____________________________________________________

____________________________________________________

____________________________________________________

____________________________________________________

____________________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. (a) Identify *two* forms of polite language that the speaker uses. **2**

ចូររកភាសាគួរសមចំនួនពីរដែលអ្នកនិយាយបានប្រើ។

(b) Compare and contrast Vutha's views on soccer with his parents' views. **4**

ចូរប្រៀបធៀបយោបល់ដូចគ្នា និងផ្ទុយគ្នារវាងវុត្ថា និងឪពុកម្ដាយរបស់គេអំពីការលេងបាល់ទាត់។

Marks

You may make notes in this space. These notes will NOT be assessed.

**Text 6**

6. (a) What hesitation does Vanna have about the topic being discussed? **3**

តើវណ្ណាមានការស្ទាក់ស្ទើរទៅលើបញ្ហាអ្វីខ្លះអំពីប្រធានបទដែលបាន
កំពុងពិភាក្សា?

(b) Explain the changes in Sophie. Support your answer with evidence from the text. **3**

ចូរពន្យល់អំពីការផ្លាស់ប្តូររបស់សុភី។
គាំទ្រចម្លើយរបស់អ្នកដោយស្រង់ភស្តុតាងពីអត្ថបទ។

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2024**

**Section 1: Listening and Responding**

**PART A**

***Text 1***

សួស្តីអស់លោកលោកស្រី!

តើលោកអ្នកមានគម្រោងដើរកម្សាន្តទេ?

ខ្មែរធួរមានមោទនភាពផ្តល់ជូននូវដំណើរកំសាន្តទេសចរណ៍មួយទៅកាន់ប្រាសាទអង្គរវត្ត ដែលអ្នកនឹងមិនអាចបំភ្លេចបាន។ មគ្គទ្ទេសក៍ទេសចរណ៍របស់យើង អាចនិយាយបានច្រើនភាសានិងមានចំណេះដឹងយ៉ាងទូលំទូលាយផ្នែកតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។

ជាពិសេសដំណើរកំសាន្តនេះក៏នឹងផ្តល់ឱកាសដល់ភ្ញៀវទេសចរណ៍ចូលរួមស្វែងយល់អំពីវប្បធម៌ក្នុងស្រុក ដូចជាការទទួលទានអាហារខ្មែរនៅក្នុងផ្ទះសហាគមន៍។

អតិថិជនក្នុងស្រុកនឹងទទួលបានការបញ្ចុះតំលៃ១០%ចាប់ពីដើមខែមករាដល់ចុងខែមីនា។

នៅក្នុងខែមេសាភ្ញៀវទាំងអស់នឹងទទួលបានការបញ្ចុះតំលៃ១៥%។

សូមកុំបោះបង់ចោលឱកាសនេះអោយសោះ!

*Text 2*

សួស្តីអ្នកទាំងអស់គ្នា សូមស្វាគមន៍ម្តងទៀតមកកាន់កម្មវិធីថ្ងៃនេះ។

ខ្ញុំនឹងចែករំលែកអំពីរបៀបធ្វើនំអន្សមខ្មែរ។ ប្រជាជនខ្មែរធ្វើនំនេះសម្រាប់ពិធីពិសេសៗ ដូចជា បុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ និងពិធីអាពាហ៍ពិពាហ៍។ ខ្ញុំមានរូបមន្តពិសេសមួយដែលខ្ញុំរៀនពីលោកយាយរបស់ខ្ញុំ។ នៅពេលធ្វើនំនេះខ្ញុំពិតជានឹកដល់អតីតកាលដែលសមាជិកគ្រួសារខ្ញុំទាំងអស់ចំណាយពេលជាមួយគ្នាដើម្បីធ្វើនំនេះ។

សូមចូលទៅមើលរូបមន្ត និងព័ត៌មានលំអិតពីរបៀបធ្វើនំអន្សមខ្មែរនៅក្នុងគេហទំព័រ cambodian-traditional food.com.au។

ខ្ញុំពិតជាសង្ឃឹមថា លោកអ្នកនឹងសាកល្បងធ្វើនំអន្សមនេះយ៉ាងរីករាយជាមួយក្រុមគ្រួសារដូចខ្ញុំដែរ។ សូមសរសេរប្រាប់ខ្ញុំអំពីបទពិសោធន៍នៃការធ្វើនំអន្សមរបស់លោកអ្នក។ សូមអរគុណ !

*Text 3*

វីរ: ណែ! មករា តើឯងចាប់អារម្មណ៍ទេថាតន្ត្រីរ៉ែបមានប្រជាប្រិយភាពខ្លាំងជាងមុននៅក្នុងប្រទេសកម្ពុជាឥឡូវ?

មករា ចាសខ្ញុំពិតជាមានការព្រួយបារម្ភថា តើវាជាទំនោរវិជ្ជមានរឺអត់។ ចម្រៀងរ៉ែបហាក់ដូចជាកំពុងផ្លាស់ប្តូរវប្បធម៌របស់យើងដែលខ្ញុំមិនសូវចូលចិត្តសោះ។

វីរ: ខ្ញុំគិតថាវាគឺជាការផ្លាស់ប្តូរមួយដ៏អស្ចារ្យសម្រាប់វិស័យតន្ត្រីរបស់យើង។ តន្ត្រីរ៉ែបផ្តល់មធ្យោបាយពិសេសមួយក្នុងការបញ្ចេញមតិខុសៗគ្នា។

មករា: តែខ្ញុំមិនចូលចិត្តពេលដែលតារាចម្រៀងប្រើភាសាបរទេសច្រើនពេកនៅក្នុងបទចម្រៀង ហើយនិងការស្លៀកពាក់របស់គេផងដែរ។

វីរ: តន្ត្រីរ៉ែបគឺជាការផ្សំបញ្ចូលនៃវប្បធម៌ខ្មែរនិងលោកខាងលិច ដូច្នេះកាយវិការសម្តែង និងពាក្យពេចន៍របស់អ្នកចម្រៀងត្រូវស្រដៀងនឹងបទចម្រៀងដើម។ ខ្ញុំគិតថាវាពិតជាជួយដល់សេដ្ឋកិច្ចខ្មែរនិងប្រជាជនយើងផងដែរ។

មករា: តើវាជួយយ៉ាងម៉េចទៅ?

វីរ: តារាចម្រៀងរ៉ែបខ្មែរអាចរកប្រាក់បានច្រើនជាងមុនទាំងក្នុងស្រុកនិងលើឆាកអន្តរជាតិ។

មករា: ខ្ញុំសប្បាយចិត្តដែលបានឮដូច្នេះ តែខ្ញុំនៅតែបារម្ភថាយើងនឹងបាត់បង់វប្បធម៌នៅពេលអនាគតពីព្រោះយុវជនយើងចូលចិត្តចំរៀងរ៉ែបខ្លាំងណាស់។ ឯងនៅចាំទេសុភាសិតខ្មែរយើងថែងថា ‘វប្បធម៌រលត់ ជាតិរលាយ’?

វីរៈ បាទខ្ញុំនៅចាំបាន។ ទោះជាយ៉ាងណាការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថលពិភពលោកនិងបណ្ដាញសង្គម ចម្រៀងវ៉ៃបអាចនាំវប្បធម៌ខ្មែរទៅកាន់ពិភពលោក។

មករា: ខ្ញុំក៏យល់អញ្ចឹងដែរ។ ខ្ញុំមិនដែលបានគិតពីចំណុចហ្នឹងទេ។ ប៉ុន្តែតើយើងអាចបញ្ចុះបញ្ចូលយុវជនឱ្យបន្តគាំទ្រតន្ត្រីបុរាណផងដោយរបៀបណា?។ វាមានសារៈសំខាន់ណាស់ក្នុងការថែរក្សាតន្ត្រីបុរាណខ្មែរយើងឲ្យនៅគង់វង្ស។

**PART B**

***Text 4***

សំណាងឯងនៅឯណា ? ម៉ាក់បានព្យាយាមទូរស័ព្ទទៅឯងជាច្រើនដង ប៉ុន្តែឯងមិនលើកសោះ។ ម៉ាក់ចង់សួរឯងថាតើមានពេលទំនេរដើម្បីទៅញ៉ាំបាយល្ងាចជាមួយយាយតានៅចុងសប្តាហ៍នេះទេ។ យាយតាកាន់តែចាស់ហើយឥឡូវនេះ ដូច្នេះវាចាំបាច់ណាស់ដែលយើងត្រូវចំណាយពេលឲ្យបានច្រើនជាមួយពួកគាត់។ ពួកគាត់ចង់ជួបឯងញឹកញាប់ជាងមុន។ បើឯងឮសារសំឡេងនេះភ្លាម សូមប្រាប់ម៉ាក់ឲ្យដឹងផងថាតើឯងអាចចូលរួមនៅថ្ងៃសៅរ៍ឬថ្ងៃអាទិត្យ។ យើងត្រូវកក់តុឲ្យបានឆាប់មុនម៉ោងប្រាំពីរជាពេលដែលភោជនីយដ្ឋានបិទទ្វារ។

*Text 5*

សូមជំរាបសួរអស់លោកលោកស្រីនិងមិត្តភក្តិទាំងអស់!

ខ្ញុំបាទឈ្មោះវុត្ថា ខ្ញុំនឹងចែករំលែកអំពីរឿងផ្ទាល់ខ្លួនរបស់ខ្ញុំ។

ខ្ញុំបានធំដឹងក្តីនៅក្នុងប្រទេសកម្ពុជា ខ្ញុំចូលចិត្តកីឡាបាល់ទាត់តាំងពីនៅក្មេង។

ការលេងបាល់ទាត់ជាមួយមិត្តភក្តិនៅពេលទំនេរមិនត្រឹមតែផ្តល់នូវភាពសប្បាយរីករាយ នោះទេប៉ុន្តែវាក៏បានជួយឱ្យយើងមានរាងកាយមាំមួននិងមានសុខភាពល្អផងដែរ ។

វាជាពេលដែលយើងសម្រាកពីការសិក្សា ហើយរីករាយជាមួយពេលវេលារបស់យើង។

បាល់ទាត់បានបង្រៀនខ្ញុំនូវមេរៀនជីវិតដ៏មានតម្លៃដូចជាការងារជាក្រុម វិន័យផ្ទាល់ខ្លួន និងជំនាញផ្សេងៗទៀត។

ទោះជាយ៉ាងណា ដំណើរជីវិតជាមួយនឹងការលេងបាល់ទាត់របស់ខ្ញុំមិនងាយស្រួល នោះទេ។

ពីដំបូងឪពុកម្តាយខ្ញុំមិនចង់ឱ្យខ្ញុំចំណាយពេលច្រើនក្នុងការលេងបាល់ទាត់នោះទេ ព្រោះគាត់យល់ឃើញថាវាជាការខ្ជះខ្ជាយពេលវេលាពីការរៀនសូត្រ។

ប៉ុន្តែនៅពេលបាល់ទាត់កាន់តែមានប្រជាប្រិយភាពនៅប្រទេសកម្ពុជា ពួកគាត់ចាប់ផ្តើម យល់ថាបាល់ទាត់បានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ខ្ញុំ។

ថ្ងៃនេះខ្ញុំសូមលើកទឹកចិត្តដល់មាតាបិតា អាណាព្យាបាល និងថ្នាក់ដឹកនាំសហគមន៍ឱ្យ ទទួលស្គាល់នូវសារៈសំខាន់នៃកីឡាបាល់ទាត់សម្រាប់យុវជនវ័យក្មេង។

សូមអរគុណសម្រាប់ការស្តាប់។

*Text 6*

វណ្ណា សួស្តីបុប្ផា តើខ្ញុំអាចសុំយោបល់ឯងបានទេ? កូនប្រុសខ្ញុំចង់ធ្វើការមិនម៉ោងប៉ុន្តែខ្ញុំមិនសូវច្បាស់ទេ។ ខ្ញុំព្រួយបារម្ភថាគេមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀនសូត្រ។

បុប្ផា: ចាសវណ្ណា, ឆ្នាំនេះកូនស្រីខ្ញុំ សុភាកំពុងធ្វើការមិនពេញម៉ោង។ ខ្ញុំពិតជាឃើញចំណុចវិជ្ជមានមួយចំនួនអំពីកូនស្រីខ្ញុំ។ នាងធ្លាប់មើលទូរស័ព្ទច្រើនណាស់។ ពេលនាងនៅផ្ទះនាងចំណាយពេលភាគច្រើនមើលទូរស័ព្ទហើយនាងមិនសូវរៀនទេ។

វណ្ណា: ហ្នឹងហើយ ខ្ញុំក៏ព្រួយចិត្តអំពីកូនប្រុសខ្ញុំដែរ។ ខ្ញុំបារម្ភថាគេនឹងអស់កំលាំងបន្ទាប់ពីធ្វើការហើយមិនអាចទៅលេងកីឡាបាន។

បុប្ផា: ខ្ញុំក៏ធ្លាប់ព្រួយចិត្តដែរប៉ុន្តែសុភាឥឡូវខុសពីមុនឆ្ងាយណាស់ នាងប្រើទូរស័ព្ទតិចជាងមុន ការប្រាស្រ័យទាក់ទងរបស់នាងក៏មានការប្រសើរឡើងជាលំដាប់ ហើយនាងក៏រៀនផងដែរ។

វណ្ណា: ប្រសើរណាស់ វាជាការផ្លាស់ប្តូរដ៏ធំមួយ។ ទោះជាយ៉ាងណាការងារដែលពួកគេធ្វើឥឡូវនេះមិនពាក់ព័ន្ធនឹងការងាររបស់ពួកគេនាពេលអនាគតនោះទេ។

បុប្ផា: ខ្ញុំគ្រាន់តែសប្បាយចិត្តដែលកូនស្រីខ្ញុំអាចរៀនពីរបៀបធ្វើការឥឡូវនេះ។ វាជាការល្អដែលយុវជនចូលរួមសកម្មភាពផ្សេងៗដែលពួកគេចូលចិត្ត ហើយធ្វើឱ្យពួកគេនៅឆ្ងាយពីទូរស័ព្ទ។

វណ្ណា: អរគុណបុប្ផាដែលបានផ្តល់យោបល់ដល់ខ្ញុំ។ ខ្ញុំនឹងនិយាយជាមួយកូនប្រុសខ្ញុំអំពីរឿងនេះ។

បុប្ផា: ខ្ញុំសង្ឃឹមថាវាអាចជួយវណ្ណាឯងបាន។

វណ្ណា: អរគុណម្តងទៀតបុប្ផា។

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

**2024** PUBLIC EXAMINATION

# Khmer

## Continuers Level

### Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2024*

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the questions that follow.

1. សារ៉ាន់

ខ្ញុំចូលចិត្តរៀនតាមអនឡាញពីព្រោះវាផ្តល់ឱ្យខ្ញុំនូវកាលវិភាគផ្ទាល់ខ្លួនដែលមានភាពបត់បែន។
សាកលវិទ្យាល័យខ្ញុំអនុញ្ញាតឱ្យយើងរៀនតាមដំណាក់កាលផ្ទាល់ខ្លួន។
វាជួយកាត់បន្ថយបញ្ហាបរិស្ថានពីព្រោះខ្ញុំមិនចាំបាច់ធ្វើដំណើរទៅសាលាជារៀងរាល់ថ្ងៃ។

2. ចាន់នី

ការសិក្សាតាមអនឡាញពិតជាពិបាកណាស់សម្រាប់ខ្ញុំ។ នៅឆ្នាំចុងក្រោយនៅវិទ្យាល័យ
ខ្ញុំអត់បានជួបជាមួយមិត្តរួមថ្នាក់ និងគ្រូដោយផ្ទាល់ទេ។ រឿងមួយទៀត ខ្ញុំមានការពិបាក
ក្នុងការសួរសំណួរនៅពេលដែលខ្ញុំអត់យល់អំពីអ្វីមួយ។ ពេលអត់បានជួបជជែកគ្នា
វាមិនមែនជាការងាយស្រួលទេសម្រាប់ខ្ញុំ។

3. អារុន

ខ្ញុំមានអារម្មណ៍ទាំងវិជ្ជមាននិងអវិជ្ជមានអំពីការរៀនតាមអនឡាញ។ ចំណុចល្អមួយ គឺវាមាន
ភាពងាយស្រួលដែលខ្ញុំមិនចាំបាច់ចំណាយពេលវេលាសម្រាប់ការធ្វើដំណើរ។
ទោះជាយ៉ាងណាខ្ញុំនឹកការជួបពិភាក្សាគ្នាក្នុងថ្នាក់រៀនណាស់ខ្ញុំមានអារម្មណ៍
ថាខ្ញុំចាប់មិនបាននូវចំណុចខ្លះនៃបទពិសោធន៍សិក្សា»។

4. ម៉ាណែត

ការសិក្សាតាមអនឡាញគឺជាជម្រើសដ៏ល្អមួយសម្រាប់ខ្ញុំដែលជាអ្នកធ្វើការ។
វាធ្វើឱ្យខ្ញុំអាចថ្លឹងថ្លែងអំពីការងារនិងការសិក្សារបស់ខ្ញុំ។
ខ្ញុំចូលចិត្តរៀនទៅតាមពេលវេលារបស់ខ្ញុំហើយជាទូទៅឯកសារផ្សេងៗតាមអនឡាញ
មានច្រើនណាស់ប៉ុន្តែទោះជាយ៉ាងណាខ្ញុំនៅតែនឹកដល់ទំនាក់ទំនងជាមួយបណ្តាញមិត្តភក្តិ
និងការជួបគ្នាដោយផ្ទាល់ជាមួយ មិត្តរួមថ្នាក់ផ្សេងទៀត។

*Vocabulary*

តុល្យភាព — balance

អនឡាញ — online

QUESTIONS

**Marks**

(a) Explain why Maneth says ‘online study has been a great option for me’ in the context of their comment. **2**

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

(b) Which two people have the most similar feelings about online study? Support your answer with evidence from the text. **3**

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

___________________________________________________________________

8. Read the text and then answer in ENGLISH the questions that follow.

## ក្រុមសន្ទនាខ្មែរ៖ សូមចូលរួមជាមួយយើងថ្ងៃនេះ!

តើអ្នកដឹងទេថា អក្សរខ្មែរមានកំណើតតាំងពីសតវត្សទី៧មកម្ល៉េះ? នៅសម័យមួយភាសាបារាំងត្រូវបានគេប្រើប្រាស់ជាភាសាផ្លូវការនៅក្នុងសាលារៀនក្នុងប្រទេសកម្ពុជា។ ខ្ញុំក៏មិនបានដឹងដែររហូតមកដល់ពេលថ្មីៗនេះ។ ខ្ញុំបានចូលរួមជាមួយក្រុមសន្ទនាខ្មែរនៅក្នុងតំបន់ខ្ញុំ ហើយខ្ញុំបានរៀនយ៉ាងច្រើនអំពីវប្បធម៌ខ្មែរដោយបាននិយាយជាមួយមនុស្សគ្រប់ស្រទាប់ក្នុងសហគមន៍ខ្មែរ។ ខ្ញុំពិតជាព្រួយបារម្ភថា ខ្ញុំមិនអាចនិយាយភាសាខ្មែរបានល្អទេ។ ខ្ញុំមានការពិបាកនិយាយជាមួយជីដូនជីតា និងក្រុមគ្រួសារនៅស្រុកខ្មែរ។ គួរឱ្យសោកស្ដាយណាស់មិនមែនមានតែខ្ញុំទេ មានយុវជនខ្មែរជាច្រើននាក់ដែលរស់នៅក្នុងប្រទេសអូស្ត្រាលីមិនបានប្រើប្រាស់ភាសាខ្មែរទៀតទេ។ នេះអាចនាំឱ្យបាត់បង់វប្បធម៌ និងភាសាខ្មែរនៅប្រទេសអូស្ត្រាលី។
ក្នុងនាមជាយុវជនខ្មែរអូស្ត្រាលីយើងមានកាតព្វកិច្ចថែរក្សាវប្បធម៌ដ៏អស្ចារ្យនិងភាសារបស់យើងឱ្យនៅគង់វង្ស។ មោទនភាពនឹងអត្តសញ្ញាណរបស់យើងគឺសំខាន់ណាស់។
តើអ្នកយល់ស្របទេ?

ដូច្នេះ តើអ្នកចង់ពង្រឹងភាសាខ្មែរ បង្កើតមិត្តភក្តិថ្មីៗ និងមានទំនាក់ទំនងជាមួយជនជាតិខ្មែរគ្រប់វ័យដែរឬទេ? សូមចូលរួមជាមួយពួកយើងដើម្បីពិសាកាហ្វេដោយឥតគិតថ្លៃនិងជជែកកំសាន្ត។ អ្នកនឹងមានការភ្ញាក់ផ្អើល ថាតើអ្នកនឹងជួបអ្នកណាខ្លះឬអ្នកនឹងរៀនអំពីអ្វី។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ CambodianLanguageClub.com។
យើងរង់ចាំជួបអ្នកទាំងអស់គ្នា!

QUESTIONS

**Marks**

(a) What is the purpose of this text? **1**

______________________________________________________________

______________________________________________________________

(b) How does the author use language to persuade their audience? **4**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

## **Part B** (Question 9)
(15 marks)

---

*Your response will be assessed on how well you:*
- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

9. Read the text and then answer the question in approximately 150 words in KHMER.

**ដំណឹងជ្រើសរើសបុគ្គលិក**

ហាងកាហ្វេបូរ៉ានគឺជាហាងកាហ្វេក្នុងស្រុកមួយដែលបានចាប់ផ្តើមអាជីវកម្មអស់រយៈពេល ៣០ឆ្នាំមកហើយ។ ដោយសារចំនួនអតិថិជនមានការកើនឡើងច្រើនជាងមុន យើងកំពុងស្វែងរកបុគ្គលិកធ្វើការផ្នែកបម្រើសេវាកម្មអតិថិជនជាបន្ទាន់។

លក្ខខណ្ឌនៃការជ្រើសរើស៖

១. មានបទពិសោធន៍ដ៏ល្អក្នុងការផ្តល់សេវាកម្មអតិថិជនពីមុនមក ហើយស្ទាត់ជំនាញទាំងភាសាអង់គ្លេស និងខ្មែរដើម្បីធ្វើការទាក់ទងយ៉ាងមានប្រសិទ្ធភាពជាមួយអតិថិជនគ្រប់ជាតិសាសន៍។

២. មានបទពិសោធន៍ក្នុងការឆុងកាហ្វេ។

៣. មានបទពិសោធន៍ធ្វើម្ហូបពីមុន / មានបទពិសោធន៍រៀបចំម្ហូបពីមុន។

៤. អាចធ្វើការរៀងរាល់ថ្ងៃសៅរ៍ឬថ្ងៃអាទិត្យ និងល្ងាចថ្ងៃព្រហស្បតិ៍និងថ្ងៃសុក្រដែរ។

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍លើមុខងារនេះ សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតដាក់ពាក្យដោយបញ្ជាក់ពីបទពិសោធន៍នានាមកកាន់ លោក ផាន់ សុវណ្ណ តាមរយៈ អ៊ីមែលcoffee@sophan.org.au ឬតាមទូរស័ព្ទលេខ ០៤២៣៥៦៩៨៧ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤។

QUESTION

Imagine that you want to apply for this position as a part time job. Write a cover letter responding to the job advertisement, convincing the employer that you are the right candidate for the job, although you don’t have all the required experience.

ឧបមាថា អ្នកចង់ដាក់ពាក្យធ្វើមុខងារនេះមិនពេញម៉ោង។
ចូរអ្នកសរសេរលិខិតដាក់ពាក្យការងារមួយតបទៅនឹងសេចក្តីប្រកាសជ្រើសរើសបុគ្គលិកដោយបញ្ចុះបញ្ចូលនិយោជកថា អ្នកជាបេក្ខជនដែលស័ក្តិសមបំផុតសម្រាប់ការងារនេះទោះបីជាអ្នកមិនមានបទពិសោធន៍ទាំងអស់ដូចក្នុងសេចក្តីប្រកាសក៏ដោយ។

---

You may make notes in this space. These notes will NOT be assessed.

This page is intentionally blank

Question 9

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

# 2024 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2024

**Section 3** (Questions 10 to 12)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. Write an article for your school newspaper about the importance of friendship in both personal and academic aspects of life.

    ចូរអ្នកសរសេរអត្ថបទមួយសម្រាប់ចុះផ្សាយក្នុងព្រឹត្តិបត្រសាលារបស់អ្នកអំពីសារៈសំខាន់នៃ
    មិត្តភាពចំពោះជីវិតផ្ទាល់ខ្លួននិងជីវិតសិក្សា។

11. You were recently challenged to go a day without spending any money. It turned out better than you expected. Write a diary entry describing your experience.

    ថ្មីៗនេះអ្នកបានប្រឈមភាពលំបាកមួយក្នុងការរស់នៅមួយថ្ងៃដោយមិនចំណាយលុយ។
    លទ្ធផលហាក់ដូចជាងាយស្រួលជាងអ្វីដែលអ្នករំពឹងទុក។
    ចូរអ្នកសរសេរក្នុងសៀវភៅកំណត់ហេតុមួយអំពីបទពិសោធន៍របស់អ្នក។

12. Write the script of a speech titled ‘Small changes, big impact’ to deliver at a Cambodian youth conference to encourage your audience to be more environmentally aware.

    ចូរអ្នកសរសេរអត្ថបទសុន្ទរកថាមួយដែលមានចំណងជើងថា
    ‘ ការផ្លាស់ប្តូរបន្តិចបន្តួច ផលប៉ះពាល់ខ្លាំង ’ ដើម្បីធ្វើបទបង្ហាញនៅក្នុងសន្និសីទយុវជនកម្ពុជា
    មួយដើម្បីលើកទឹកចិត្តទស្សនិកជនរបស់អ្នកឱ្យយល់ដឹងអំពីបរិស្ថានឱ្យកាន់តែច្បាស់។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question Number:



PLEASE TURN OVER

**End of Section 3**